# តើជំងឺកញ្ជ្រឹលងាយឆ្លងកម្រិតណា?




Joe រស់នៅទីក្រុងស៊ីអាថល។ ថ្មីៗនេះ គាត់បានធ្វើដំណើរទៅកន្លែងដែលគាត់បានឆ្លងជំងឺកញ្ជ្រឹល។




Joe មានអាការៈគ្រុនក្តៅ និងមិនស្រួលខ្លួន។ គាត់មិនដឹងថាគាត់មានផ្ទុកជំងឺកញ្ជ្រឹលទេ។




Joe មិនទាន់មានកន្ទួលទេ ប៉ុន្តែគាត់អាចចម្លងជំងឺយ៉ាងរហ័សរួចទៅហើយ។ គាត់បញ្ចេញវីរុសទៅក្នុងខ្យល់ នៅពេលគាត់ដកដង្ហើមចេញ និយាយ ក្អក ឬកណ្តាស់។







វីរុសរសាត់ក្នុងខ្យល់ សូម្បីក្រោយពេល Joe ចាកចេញ។ វាអាចបន្តស្ថិតក្នុងខ្យល់រហូតដល់ 2 ម៉ោង។ នរណាដែលឆ្លងកាត់បន្ទប់រង់ចាំអាចនឹងស្រូបវាតាមដង្ហើមចូល។




តើមានអ្វីកើតឡើង ប្រសិនបើក្នុងចំណោមមនុស្សទាំងនេះគ្មាននរណាបានចាក់វ៉ាក់សាំង Measles, Mumps and Rubella (MMR, កញ្ជ្រឹល ស្រឡទែន និងស្អូច) ហើយគ្មាននរណាធ្លាប់កើតជំងឺកញ្ជ្រឹល?

**រហូតដល់ 9 ក្នុងចំណោម 10 នាក់នឹងឆ្លងជំងឺកញ្ជ្រឹល។**




ចុះបើពួកគេបានចាក់វ៉ាក់សាំងទាំងអស់គ្នា?

**ភាគច្រើនគឺគ្មាននរណានឹងឆ្លងជំងឺកញ្ជ្រឹលឡើយ។**

វ៉ាក់សាំងជំងឺកញ្ជ្រឹល (MMR) ផ្តល់ការការពារខ្លាំងណាស់។ **2 ដូសមានប្រសិទ្ធភាពប្រហែល 97% ក្នុងការបង្ការកុំឱ្យឆ្លង។**

អ្នកមិនចាំបាច់ចាក់ដូសជំរុញបន្ថែមទេ ដូសទាំងនោះមានប្រសិទ្ធភាពការពារបានមួយជីវិត!

[kingcounty.gov/measles](kingcounty.gov/measles)



Khmer